# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

០៧-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៤៤ ស្តីពីការតែងតាំង ឯកឧត្តម ចំនួន ០៤ រូប ជាទីប្រឹក្សា ឯកឧត្តម **ខួន ញឹល** អនុប្រធានទី ១ រដ្ឋសភា នីតិកាលទី ៣ ៥៩៤៧

១៤-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៥២ ស្តីពីការប្រោសព្រះរាជទាន ចំពោះលោក **ចាន់ សុផល** នូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ៥៩៤៨

១៨-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៥៣ ស្តីពីការតែងតាំង លោកស្រី **ថ្នាក់ សារុំ** ជា ឧកញ៉ា ៥៩៤៩

១៨-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៥៤ ស្តីពីការតែងតាំង លោក **ឡាច ខុច** ជា ឧកញ៉ា ៥៩៥០

## II-ក្រុមប្រឹក្សាធម្មនុញ្ញ

១៨-៨-២០០៦ -សេចក្តីសំរេចលេខ ០៨១/០០៨/២០០៦ កបធ.ច ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ៥៩៥១

## III-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

១៧-៨-២០០៦ -អនុក្រឹត្យលេខ ៨១ អនក្រ.បក ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ មកជា អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ៥៩៥៣

១៨-៨-២០០៦ -អនុក្រឹត្យលេខ ៨២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៥៩៥៥

១៨-៨-២០០៦ -អនុក្រឹត្យលេខ ៨៣ អនក្រ.បក ស្តីពីការកែប្រែរបបជីវភាពសម្រាប់ទណ្ឌិត និងពិរុទ្ធជន ៥៩៥៧

១៧-៨-២០០៦ -អនុក្រឹត្យលេខ ៥៥៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥៩៥៩

១៧-៨-២០០៦ -អនុក្រឹត្យលេខ ៥៥៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥៩៦២

១៧-៨-២០០៦ -អនុក្រឹត្យលេខ ៥៥៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥៩៦៣

១៧-៨-២០០៦ -អនុក្រឹត្យលេខ ៥៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៩៦៤

១៧-៨-២០០៦ -អនុក្រឹត្យលេខ ៥៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៩៦៥

១៧-៨-២០០៦ -អនុក្រឹត្យលេខ ៥៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៩៦៦

## ២-សេចក្តីសំរេច


១៧-៨-២០០៦ -សេចក្តីសំរេចលេខ ៣៦ សសរ ស្តីពីការបង្កើតគណៈកម្មការ ដើម្បីកំណត់អាសនៈរដ្ឋសភា សម្រាប់នីតិកាលទី ៤ ៥៩៦៧


## III-ការិយាល័យក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


០៧-៨-២០០៦ -ប្រកាសលេខ ៦០៧ សហវ.ប្រក ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ ៥៩៦៩

១៥-៨-២០០៦ -សេចក្តីសំរេចលេខ ០០៧ សសរ.សហវ.ពដ ស្តីពីការកែប្រែសមាសភាពអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ខេត្តបន្ទាយមានជ័យ ៥៩៧៣

១៦-៨-២០០៦ -សេចក្តីជូនដំណឹងលេខ ០២៤ សហវ.ពដ ស្តីពីការប្រើប្រាស់វិក្កយបត្រសំរាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ៥៩៧៦


## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


២២-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ូះ អង្គរ** ៥៩៧៧

២២-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦០៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ី ស៊ីន គូ ហ៊ិន** ៥៩៧៩

២៣-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មូន អ៊ែតវើថាយស៊ីង** ៥៩៨១

២៣-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាយហ៊ួ ស៊ែឡម** ៥៩៨៣

២៣-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថាច់ន្ទរិទ្ធ អភិវឌ្ឍន៍** ៥៩៨៥

២៣-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីង រិទ្ធី គ្រុប** ៥៩៨៧

២៣-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦១៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេនជល ត្រាវែល (អេ ធី)** ៥៩៨៩

២៦-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦១៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថេកនេនធីធី ខូ អិលធីឌី** ៥៩៩១

| | | |
|---|---|---|
| ២៦-៦-២០០៦ | -លិខិតបញ្ជាក់លេខ ១៦១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ីហ្សនេស ដាយនែមីកស៍ (ខេមបូឌា) ខូ អិលធីឌី** | ៥៩៩៣ |
| ២៧-៦-២០០៦ | -លិខិតបញ្ជាក់លេខ ១៦២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សៀក អេគ្រីខលឈើ & ឌីវើឡុបមេន** | ៥៩៩៥ |
| ២៨-៦-២០០៦ | -លិខិតបញ្ជាក់លេខ ១៦២១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហុង-ឈីន ត្រាវែល & ធួរ** | ៥៩៩៧ |
| ២៨-៦-២០០៦ | -លិខិតបញ្ជាក់លេខ ១៦២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វេលស៍ អេឃើដីមី (ខេមបូឌា)** | ៥៩៩៩ |
| ២៨-៦-២០០៦ | -លិខិតបញ្ជាក់លេខ ១៦២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច អេច អេច ហូលឌីង** | ៦០០១ |
| ២៩-៦-២០០៦ | -លិខិតបញ្ជាក់លេខ ១៦៣២ ពណ.នតក ស្តីពីការអនុញ្ញាតជាគោលការណ៍អោយបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន " **ម៉ារ៉ូណាគា សូជី** " ប្រចាំរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីនៅ ប្រទេសជប៉ុន | ៦០០៣ |
| ៣០-៦-២០០៦ | -លិខិតបញ្ជាក់លេខ ១៦៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី សុវណ្ណភូមិ អ៊ិនវេសមេន** | ៦០០៤ |

នស/រកត/០៨០៦/៣៤៤

# ព្រះរាជក្រឹត្យ

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា និងសំដែងការទុកចិត្តទៅលើសមាសភាព រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ ឯកឧត្តម ងួន ញិល ប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងជាទីប្រឹក្សា ឯកឧត្តម ងួន ញិល អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៣ :

១/- ឯកឧត្តម អ៊ុន គីម ឋានៈស្មើ រដ្ឋលេខាធិការ
២/- ឯកឧត្តម ហ៊ាន ឈៀនឈុន ឋានៈស្មើ រដ្ឋលេខាធិការ
៣/- ឯកឧត្តម ពុទ្ធី រុមយេទី ឋានៈស្មើ អនុរដ្ឋលេខាធិការ
៤/- ឯកឧត្តម ឈិន លីមសាឌុង ឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា២ : ប្រធានរដ្ឋសភា និងសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៣៣៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៨ ៧ ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

ឃុន ជិនកេន

៣១ល.០៧០៥.៣៦៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០០៦

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៦/៣៥២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

ចំពោះ

លោក **ចាន់ សុផល**

នូវ

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល-០៦០៨-៣៧៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០០៦

លេខ ៣៣៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៦/៣៥៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

តែងតាំង

លោកស្រី **ប្រាក់ សារុំ**

ជា

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

តរល.០៦០៥.៣៧៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៦*

លេខ : ៣៣៩៦.ល
**ដើម្បីចម្លងចែកជូន**
រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៦/៣៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

តែងតាំង

លោក **ឡាច ឡូច**

ជា

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ចរល-០៤០៨.៣៧៥*

*នៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០០៦*

លេខ : ៣៤០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១០៩ /០០៩ /២០០៦

ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦

**សេចក្ដីសម្រេច**

លេខ :០៨១/០០៨/២០០៦ កបធ.ច

ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៣៥/០០១/២០០០ កបធ.ច ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០០
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/០៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ប្រកាសឱ្យប្រើច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតលេខ ៩១៦ រស ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ របស់សម្ដេច **ហេង សំរិន** ប្រធានរដ្ឋសភាស្នើសុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ វេលាម៉ោង ១០ និង ១៣ នាទី ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់វាក្យខ័ណ្ឌទី ២ ឃ្លាទី ១ ចែងថា " *បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសអោយប្រើ* " ។ សំណើរបស់សម្ដេច **ហេង សំរិន** ប្រធានរដ្ឋសភា

លេខ៩១៦រស ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០០៦ វេលាម៉ោង១០និង១៣ នាទី គឺស្របតាមរដ្ឋធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំឱ្យពិនិត្យធម្មនុញ្ញភាពនេះ មកពិនិត្យបាន ។

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ ។
- យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា មិនមានអ្វីដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញរដ្ឋសភា នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្រប កាលពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៦ នាសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ មកជា អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពី ការបង្កើតនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ចំណុះក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ៈ** ត្រូវបានកែសំរួល អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ មកជា អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ។

**មាត្រា ២:** ត្រូវបានបំបែកនាយកដ្ឋានពន្ធនាគារ ចេញពីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដោយបង្កើតទៅជាអង្គភាពមួយដោយឡែក ដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៣:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ដូចមាត្រា៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ៩៧ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៤.០០០ លានរៀល (បួនពាន់លានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) របស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ពិគ្រោះតំលៃ និង អនុវត្តកិច្ចសន្យាបន្តផ្គត់ផ្គង់ឯកសារសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និង សំភារៈ ដើម្បីបំរើអោយយុទ្ធនាការចល័តចុះបញ្ជីអត្រានុកូលដ្ឋានទូទាំងប្រទេសក្នុងដំណាក់កាលទី ២ ឆ្នាំ ២០០៦ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១៧ ខែ ៨/៧ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ...៨៧៣...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកែប្រែរបបជីវភាពសម្រាប់ទណ្ឌិត និងពិរុទ្ធជន

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីប្រាក់បំណាច់ និង របបឧបត្ថម្ភជីវភាពចំណាយសម្រាប់ផ្តល់ដល់មុខសញ្ញាមួយចំនួន

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១ :** អនុក្រឹត្យនេះមានគោលដៅបំពេញបន្ថែម និងកែប្រែរបបជីវភាពសម្រាប់ទណ្ឌិត និងពិរុទ្ធជន ដែលជាប់ឃុំក្នុងពន្ធនាគារ ឬមន្ទីរឃុំឃាំងទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយផ្តល់បន្ថែមម្នាក់ក្នុងមួយថ្ងៃចំនួន ៥០០រ (ប្រាំរយរៀល) ទៀត ដែលជាសរុបឡើងដល់ចំនួន ១.៥០០រ (មួយពាន់ប្រាំរយរៀល) សម្រាប់ម្នាក់ក្នុងមួយថ្ងៃ ។

**មាត្រា ២ :** រាល់ការកំណត់ទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងគ្រប់អភិបាលខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៣

-ឯកសារ និង កាលប្បវត្តិ.

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៥៥៥...អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន៩០គ្រឿង ជូនមន្ត្រីរាជការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ចំនួន៩០រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច លើការងារជំនាញអាកាសចរកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ជា** | **អូន** | អគ្គនាយក |
| ២-លោក | **សូ** | **ណាសុត** | អនុប្រធាននាយកដ្ឋាន វិស្វកម្មអាកាសយានដ្ឋាន |
| ៣-លោក | **គីម** | **សាន** | នាយករង អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |
| ៤-លោក | **ឆៀង** | **វុឌ្ឍី** | នាយករង អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |

**ខ-មេដាយប្រាក់ការងារ :**

| | | | |
|---|---|---|---|
| -លោក | **សន** | **សុផល** | នាយករង អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |

**គ-មេដាយសំរឹទ្ធការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **ម៉ីង** | **សត្យា** | អនុប្រធាននាយកដ្ឋានផែនការ និតិកម្ម |
| ២-លោក | **ស៊ីន** | **ម៉ិនថាត** | អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ ហិរញ្ញវត្ថុ |
| ៣-លោក | **ឡេង** | **វណ្ណារ័ត្ន** | នាយករង អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |
| ៤-លោក | **អង្គ** | **អស្សារាវុឌ្ឍ** | អនុប្រធាននាយកដ្ឋាន ដឹកជញ្ជូនផ្លូវអាកាស |

| | | |
|---|---|---|
| ៥-លោក | ឃួន ស៊ីនាថ | អនុប្រធាននាយកដ្ឋានវិស្វកម្មអេឡិចត្រូនិច |
| ៦-លោក | ជា សុខខេង | អនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ |
| ៧-លោក | អួន ទិត្យរៈ | អធិការរង អធិការដ្ឋាន |
| ៨-លោក | អួន សំអាត | ប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិ សៀមរាប |
| ៩-លោក | ម៉ិល ដារ៉ារិទ្ធ | ប្រធានការិយាល័យ វិស្វកម្មអាកាសយានដ្ឋាន |
| ១០-លោក | គឹម ស្រាយ | អនុប្រធានការិយាល័យផែនការនិតិកម្ម |
| ១១-លោក | ម៉ី កុសល | អនុប្រធានការិយាល័យ សន្តិសុខ |
| ១២-លោក | សោម សារ៉ាន | អនុប្រធានការិយាល័យ សន្តិសុខ |
| ១៣-លោកស្រី | យ៉ាន់ មុនី | អនុប្រធានការិយាល័យ ដឹកជញ្ជូនផ្លូវអាកាស |
| ១៤-លោក | យី សុវណ្ណគីរី | អនុប្រធានការិយាល័យ រដ្ឋបាល-បុគ្គលិក |
| ១៥-លោក | ទ្រី ពន្លឺរដ្ឋ | អនុប្រធានការិយាល័យ រដ្ឋបាល-បុគ្គលិក |
| ១៦-លោក | ម៉ុក បូរ៉ា | អនុប្រធានការិយាល័យ រដ្ឋបាល-បុគ្គលិក |
| ១៧-លោក | ធន់ ពៅ | អនុប្រធានការិយាល័យ រដ្ឋបាល-បុគ្គលិក |
| ១៨-លោក | សួន តូម៉ា | អនុប្រធានការិយាល័យ រដ្ឋបាល-បុគ្គលិក |
| ១៩-លោក | យឹម ម៉េងអៀង | អនុប្រធានការិយាល័យ ផ្គត់ផ្គង់ ហិរញ្ញវត្ថុ |
| ២០-កញ្ញា | សាវឿន ហេមវតី | អនុប្រធានការិយាល័យ ផ្គត់ផ្គង់ ហិរញ្ញវត្ថុ |
| ២១-លោក | សោភ័ណ នរិនរិទ្ធ | អនុប្រធានការិយាល័យ ផ្គត់ផ្គង់ ហិរញ្ញវត្ថុ |
| ២២-លោក | ស៊ាន សំណោរស្ព | អនុប្រធានការិយាល័យ ប្រតិបត្តិការនិងសុវត្ថិភាពហោះហើរ |
| ២៣-លោកស្រី | ម៉ិន វណ្ណឌី | អនុប្រធានការិយាល័យ ប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ |
| ២៤-លោកស្រី | សំ ចាន់ថុល | អនុប្រធានការិយាល័យ ប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ |
| ២៥-លោក | សែម ម៉ិនរិទ្ធ | អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |
| ២៦-លោក | ម៉ាន់ ណារ៉ាក់ | អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |
| ២៧-លោក | ហួន ឡុងហួត | អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |
| ២៨-លោក | ម៉ុល សារី | អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |
| ២៩-លោក | រ័ត្ន សុគន្ធា | អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិសៀមរាប |
| ៣០-លោកស្រី | ឡុង តារាម្យ | អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិសៀមរាប |
| ៣១-លោក | យ៉ែម ម៉ុន | នាយករង អាកាសយានដ្ឋាន ស្ទឹងត្រែង |
| ៣២-លោក | ផន ផល្លី | នាយករង អាកាសយានដ្ឋាន កងកេង |
| ៣៣-លោក | ហាច់ រុន | មន្ត្រីគ្រប់គ្រងរដ្ឋបាល រដ្ឋបាល-បុគ្គលិក |
| ៣៤-លោកស្រី | ម៉ៃ ដារ៉ាណេ | មន្ត្រីគ្រប់គ្រងរដ្ឋបាល ផ្គត់ផ្គង់ ហិរញ្ញវត្ថុ |
| ៣៥-លោក | ឈាង គឹមសុខ | មន្ត្រីគ្រប់គ្រងរដ្ឋបាល ដឹកជញ្ជូនផ្លូវអាកាស |
| ៣៦-លោក | ឈឹម មីសីលា | មន្ត្រីគ្រប់គ្រងរដ្ឋបាល ដឹកជញ្ជូនផ្លូវអាកាស |
| ៣៧-លោក | ណុប ចំនួនវន្នី | មន្ត្រីគ្រប់គ្រងរដ្ឋបាល ប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ |
| ៣៨-លោក | ម៉ៅ ញ៉ាញ់ | មន្ត្រីគ្រប់គ្រងរដ្ឋបាល អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |

| | | | |
|---|---|---|---|
| ៣៩-លោក | **គង់** | **ម៉ិនឈេង** | មន្ត្រីក្រមការ វិស្វកម្មអាកាសយានដ្ឋាន |
| ៤០-លោកស្រី | **ក្មុយ** | **សារុន** | លេខាធិការ រដ្ឋបាល-បុគ្គលិក |
| ៤១-លោក | **ជឿន** | **គីមហេង** | លេខាធិការ វិស្វកម្មអេឡិចត្រូនិច |
| ៤២-កញ្ញា | **អ៊ឹម** | **សោភា** | លេខាធិការ ប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ |
| ៤៣-លោក | **សរ** | **សុត្ថាយុទ្ធ** | លេខាធិការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |
| ៤៤-លោក | **ស៊ុំ** | **សុផារ៉ា** | លេខាធិការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |
| ៤៥-លោក | **លន** | **ធីរិទ្ធ** | លេខាធិការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៥៥៧...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងព័ត៌មាន

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន០១គ្រឿង ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោក **ឌួច ស្រ៊ុន** អនុប្រធានមន្ទីរព័ត៌មាន ខេត្តរតនគីរី ដែលកន្លងមក លោកបានខិតខំយ៉ាងសកម្ម និងមានស្នាដៃល្អជាច្រើនក្នុងការបំរើជាតិមាតុភូមិ ហើយបានទទួលមរណភាពដោយរោគាពាធ ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន និង អភិបាលខេត្តរតនគីរី ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល ៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងព័ត៌មាន

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយថ្នាក់ការងារ** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោកស្រី **មាស ម៉ានី** ប្រធានការិយាល័យវិទ្យុ នៃមន្ទីរព័ត៌មាន ខេត្តកំពង់ឆ្នាំង ដែលកន្លងមកលោកស្រីមានស្នាដៃល្អជាច្រើនក្នុងការបំរើជាតិមាតុភូមិ ហើយបានទទួលមរណភាព ដោយគ្រោះថ្នាក់ចរាចរ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ ៧ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៥៥៧...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

ៗៗ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ *LUTHERAN EDUCATION IN THE ADELIDE HILLS , AUSTRALIA* ដែលបានឧបត្ថម្ភថវិកា ចំនួន ២៣.៨៩៧ ដុល្លារ អាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង បង្គន់អនាម័យ ០២បន្ទប់ និងបំពាក់សម្ភារៈសិក្សា នៅសាលាបឋមសិក្សា ល្វីម ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ...៧ ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៥៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន ***AEON CREDIT SERVICE*** ដែលបានឧបត្ថម្ភថវិកា ចំនួន ២៨.០០០ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង ព្រមទាំងបំពាក់សម្ភារៈសិក្សា នៅសាលាបឋមសិក្សា ថ្នល់ជ័យ ក្នុងឃុំពពឹស ស្រុកព្រៃវែង ខេត្តព្រៃវែង ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមសហព័ន្ធតូស៊ីបា (*Toshiba Group Union*) ដែលបានឧបត្ថម្ភថវិកា ចំនួន ២៨.០២៥ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង អណ្តូងទឹក ០១ ទោងសំរាប់កុមារលេង និងបំពាក់សម្ភារឹមសិក្សា នៅសាលាបឋមសិក្សា ភូមិចាន់ ឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៦*

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៦ អនក្រ.សរ

## សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការ

## ដើម្បីកំណត់អាសនៈរដ្ឋសភាសម្រាប់នីតិកាលទី ៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងមាត្រា៧ និងមាត្រា៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការកំណត់អាសនៈរដ្ឋសភាសម្រាប់នីតិកាលទី៤ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- | តំណាងគណបក្សប្រជាជនកម្ពុជា | មួយរូប |
| ២- | តំណាងគណបក្សហ្វុនស៊ិនប៉ិច | មួយរូប |
| ៣- | តំណាងគណបក្សសមរង្ស៊ី | មួយរូប |
| ៤- | តំណាងក្រសួងមហាផ្ទៃ | ពីររូប |
| ៥- | នាយកនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | មួយរូប |

**ប្រការ ២.-**

គណៈកម្មការនេះដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយរូប ដែលជ្រើសតាំងក្នុងចំណោមសមាជិកគណៈកម្មការដោយការបោះឆ្នោតតាមមតិភាគច្រើនដាច់ខាតពីសមាជិកគណៈកម្មការនេះ។

**ប្រការ ៣.-**

គណៈកម្មការខាងលើនេះមានតួនាទី និងភារកិច្ចសិក្សាស្រាវជ្រាវ ធ្វើរបាយការណ៍ និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីការបន្ថែមអាសនៈ ឬការរក្សាទុកចំនួនអាសនៈនៅដដែល ដោយផ្អែកលើស្ថានភាពប្រជាពលរដ្ឋ ស្ថានភាពភូមិសាស្ត្រ សង្គម និងសេដ្ឋកិច្ច។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខៈ ៦០៩ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៦

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ

*** ៚ ***

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ករត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ បក ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- យោងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ ៩០ សជណ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥
- យោងស្មារតីនៃអង្គប្រជុំបើកទូលាយ របស់គណៈកម្មាធិការដឹកនាំដើម្បីអភិវឌ្ឍន៍ផ្នែកឯកជននាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ
- យោងតាមតម្រូវការ និងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១:** បង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ២:** ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៣:** ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ មានតួនាទីដូចតទៅ ÷

១- កសាង និងអនុវត្តនូវកម្មវិធីគ្រប់គ្រងហានិភ័យ សំរាប់ទីចាត់ការគយនិងរដ្ឋាករ ដោយឈរលើគោលការណ៍នៃកិច្ចសម្រួលពាណិជ្ជកម្ម ក្នុងពេលជាមួយនឹងការការពារចំណូលពន្ធនិងអាករ ការត្រួតពិនិត្យចរាចរទំនិញខុសច្បាប់ ឬទំនិញរត់ពន្ធ និងចូលរួមពង្រឹងនូវសន្តិសុខនៃការនាំចេញ និងនាំចូល។

២- ជំរុញឱ្យអង្គភាពគយនិងរដ្ឋាករនានា អនុវត្តនូវគោលការណ៍នៃការគ្រប់គ្រងហានិភ័យ និងការជ្រើសរើសមុខសញ្ញាក្នុងប្រតិបត្តិការរបស់ខ្លួន ស្របតាមខ្លឹមសារនៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដោយគ្រប់គ្រង ត្រួតពិនិត្យ និងវាយតំលៃកិច្ចការទាំងនេះ។

៣- ជូនយោបល់ដល់ថ្នាក់ដឹកនាំទីចាត់ការគយនិងរដ្ឋាករ ពីការវិវត្តនៃកម្មវិធីគ្រប់គ្រងហានិភ័យ និងរៀបចំជារបាយការណ៍ និងការវិភាគ អនុលោមតាមខ្លឹមសារនៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ។

៤- ធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ លើអាជីវករ ឬបុគ្គលពាក់ព័ន្ធ ដោយផ្អែកលើហានិភ័យដែលបានរកឃើញ។

៥- អនុវត្តនូវមុខងារ និងភារកិច្ចនានាដូចមានចែងក្នុងប្រការ ១១ នៃប្រកាសលេខ ៩២០ សហវ គរ ប្រក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីចាត់ការគយនិងរដ្ឋាករ។

៦- ប្រើប្រាស់កំលាំងគយនិងរដ្ឋាករក្រោមឱវាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចាំបាច់ ដើម្បីសំរេចឱ្យបាននូវតួនាទីដូចរៀបរាប់ខាងលើ។

**ប្រការ ៤:** ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ មានសិទ្ធិដូចតទៅ ÷

១- ធ្វើជាចំណុចទំនាក់ទំនងតែមួយរបស់ទីចាត់ការគយនិងរដ្ឋាករ ជាមួយភ្នាក់ងារ ឬអង្គភាពផ្សេងទៀត ដើម្បីទំនាក់ទំនងផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងទំនិញ មធ្យោបាយដឹកជញ្ជូន និងមុខសញ្ញាដែលមានហានិភ័យខ្ពស់ចំពោះអង្គភាពគយនិងរដ្ឋាករ តាមរយៈ ÷

- ការទំនាក់ទំនងស្រាវជ្រាវរកឯកសារ និងព័ត៌មាននានា ពីបណ្តាអង្គភាពក្រោមឱវាទទីចាត់ការគយនិងរដ្ឋាករ ហើយក្នុងករណីចាំបាច់ តំរូវឱ្យអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធផ្តល់ព័ត៌មានជាប្រចាំតាមទំរង់ជាក់លាក់ ដែលយល់ថាមានប្រយោជន៍។

- ការទំនាក់ទំនងស្រាវជ្រាវរកឯកសារ និងផ្តល់ឯកសារមួយចំនួនទៅវិញទៅមកជាមួយនឹងភ្នាក់ងារ ឬអង្គភាពជំនាញនៃក្រសួង ឬស្ថាប័នមានសមត្ថកិច្ចនានានៃរាជរដ្ឋាភិបាល ដោយមានការអនុញ្ញាតជាមុនពីទីចាត់ការគយនិងរដ្ឋាករ។
- ការទទួលព័ត៌មាន និងឯកសារនានាពីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត ផ្នែកឯកជន និងរដ្ឋបាលគយបរទេស ពាក់ព័ន្ធនឹងការនាំចេញនាំចូលទំនិញ ដើម្បីសំណូមពរនៃការកំណត់ហានិភ័យ ដោយមានការអនុញ្ញាតជាមុនពីទីចាត់ការគយនិងរដ្ឋាករ។

២- ចេញសេចក្តីណែនាំតម្រង់ទិសដល់អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធនានាពីមុខសញ្ញាទំនិញ និងមធ្យោបាយដឹកជញ្ជូនដែលត្រូវត្រួតពិនិត្យដោយគយ ពីកំរិតនៃការត្រួតពិនិត្យទំនិញដោយផ្អែកលើការវាយតំលៃហានិភ័យ ហើយអាចចាត់តាំងមន្ត្រីក្រោមឱវាទចូលរួមដោយផ្ទាល់ក្នុងការត្រួតពិនិត្យទំនិញដែលស្ថិតក្នុងមុខសញ្ញាហានិភ័យនោះ។

៣- បញ្ជូនមន្ត្រីមួយចំនួននៃការិយាល័យនេះទៅបំពេញភារកិច្ចនៅតាមអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ ដើម្បីកំណត់ទិសដៅ និងអនុវត្តនូវការគ្រប់គ្រងហានិភ័យ ក្នុងករណីយល់ថាចាំបាច់។

៤- ប្រមូលផ្តុំ និងផ្ទៀងផ្ទាត់នូវលទ្ធផលនៃការត្រួតពិនិត្យទំនិញ និងការអនុវត្តផែនការនានានៃការគ្រប់គ្រងហានិភ័យ។

៥- ប្រមូលពន្ធអាករ ឬប្រាក់ពិន័យបើមាន ពីលទ្ធផលការងារសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដែលស្ថិតក្នុងមុខសញ្ញាហានិភ័យ និងមានសិទ្ធិទទួលនូវប្រាក់រង្វាន់ ស្របតាមខ្លឹមសារប្រកាសស្តីពីការបែងចែកផលដែលបានមកពីប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ និងបទបញ្ញត្តិផ្សេងទៀតជាធរមាន។

៦- គ្រប់គ្រងការចេញ និងត្រួតពិនិត្យការអនុវត្ត "លិខិតបញ្ជា" របស់ទីចាត់ការគយនិងរដ្ឋាករ ឱ្យឃាត់ទុកជាបណ្តោះអាសន្ន ឱ្យត្រួតពិនិត្យលំអិត ឬឱ្យត្រួតពិនិត្យឡើងវិញតាមមុខសញ្ញាទំនិញ មធ្យោបាយដឹកជញ្ជូន និងអាជីវកម្មដ្ឋាន ឬលំនៅស្ថានដែលសង្ស័យថាពាក់ព័ន្ធនឹងបទល្មើសគយ ស្របតាមច្បាប់ និងបទបញ្ញត្តិជាធរមាន។

**ប្រការ ៥:** ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ មានភារកិច្ចដូចតទៅ :

១- កសាងផែនការគ្រប់គ្រងហានិភ័យលំអិត ដើម្បីកំណត់មុខទំនិញ មធ្យោបាយដឹកជញ្ជូននានា ឆ្លងកាត់មាត់ច្រកព្រំដែន និងមុខសញ្ញាដែលមានហានិភ័យខ្ពស់។

២- តាមដានអនុវត្តកិច្ចព្រមព្រៀងអន្តរស្ថាប័នជាមួយនឹងភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត ដោយអនុលោមតាមអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដោយសម្របសម្រួលការងាររវាងទីចាត់ការគយនិងរដ្ឋាករ និងស្ថាប័នឯកទេសនានា។

៣- សហការជាមួយភ្នាក់ងារ ឬអង្គភាពជំនាញនៃក្រសួង ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងហានិភ័យ រាប់បញ្ចូលទាំងការងារផ្លាស់ប្តូរព័ត៌មាន និងការផ្តល់នូវជំនួយទៅវិញទៅមក។

៤- ជួយការិយាល័យ និងសាខាគយនិងរដ្ឋាករនានា រៀបចំនូវផែនការប្រតិបត្តិនៃការគ្រប់គ្រងហានិភ័យ។

៥- កសាងកម្មវិធី និងផ្តល់នូវការហ្វឹកហ្វឺនដល់ភ្នាក់ងារគយនិងរដ្ឋាករ អំពីការគ្រប់គ្រងហានិភ័យ។

៦- កសាង និងកាន់កាប់នូវបញ្ជីទំនិញហាមឃាត់ ឬជាប់កំរិតកំណត់ ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ ASYCUDA និងសំរាប់ចែកចាយដល់គ្រប់អង្គភាពគយនិងរដ្ឋាករ និងផ្តល់នូវការណែនាំ ថាតើទំនិញទាំងនេះ នឹងត្រូវផ្តល់ប្រព្រឹត្តកម្មដូចម្តេច ដោយមន្ត្រីគយនិងរដ្ឋាករ។

៧- កសាង និងកាន់កាប់នូវទិន្នន័យពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ រួមមានការកត់ត្រាលើកំណត់ហេតុបទល្មើសគយ ព័ត៌មានពីមុខសញ្ញាសង្ស័យថាជាអ្នករត់ពន្ធ ឬជាអ្នករំលោភច្បាប់ និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត។

៨- ប្រមូល និងវិភាគព័ត៌មានពីប្រភពនានា ចាត់ចែងវិភាគហានិភ័យ កសាងមុខសញ្ញាហានិភ័យ និងលក្ខណៈវិនិច្ឆ័យជ្រើសរើស និងមុខសញ្ញាដោយឡែកនានា និងផ្សព្វផ្សាយដល់អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ។

៩- គ្រប់គ្រង តាមដាន និងវាយតំលៃការអនុវត្តនូវផែនការគ្រប់គ្រងហានិភ័យដោយអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ។

១០- តាក់តែងរបាយការណ៍នានា ដែលជាមូលដ្ឋាននៃការវាយតំលៃប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងហានិភ័យនៅទីចាត់ការគយនិងរដ្ឋាករ។

១១- កសាង និងអនុវត្តផែនការសវនកម្មផ្ទៃក្នុងអង្គភាពគយនិងរដ្ឋាករ និងចាត់ចែងធ្វើសវនកម្មក្រោយការបញ្ចេញទំនិញពីគយ លើមុខសញ្ញាហានិភ័យនានា។

១២- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ទីចាត់ការគយនិងរដ្ឋាករ។

**ប្រការ ៦:** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧:** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**គាត ឈន់**

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្តក្រុងដែលពាក់ព័ន្ធ
“ដើម្បីជូនជ្រាប និងសុំកិច្ចសហការអនុវត្ត”
- ដូចប្រការ៧ “ដើម្បីអនុវត្ត”
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រ កម្ពុជា

*Kingdom Of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

លេខ.០០១៧...សសរ.សហវ.ពដ

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហាឆ្នាំ ២០០៦

## សេចក្តីសំរេច

## ស្តីពី

## ការកែប្រែសមាសភាពអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

## ខេត្តបន្ទាយមានជ័យ

---

### ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧០៤.១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱយ ច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ . ប្រកាសឱយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៥៨-អនក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ២២៤ ប្រក-សហវ-ពដ ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

- បានឃើញសេចក្តីសំរេចលេខ ០០៤-សសរ-សហវ-៣៨ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៣៩៣ ប្រក-សហវ-៣៨ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ១៩៩៩ ស្តីពីការកែប្រែសមាសភាពគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០១ សហវ.៣៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញសំណើរបស់ប្រធានអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់នៅខេត្តបន្ទាយមានជ័យលេខ ១៦៥៩ ខបជ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦ ស្តីពីសំណើកែសំរួលសមាសភាពអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ខេត្តបន្ទាយមានជ័យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅខេត្តបន្ទាយមានជ័យ ។

## សំរេច :

**ប្រការ១:** សមាសភាពនៃអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់នៅខេត្តបន្ទាយមានជ័យ ដែលមាននៅក្នុងសេចក្តីសំរេចលេខ ០០១ សហវ.៣៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ត្រូវបានកែប្រែដូចតទៅ :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម អន ស៊ី | អភិបាលខេត្ត | ជាប្រធាន |
| ២- | ឯកឧត្តម សរ ចំរុង | អភិបាលរងខេត្ត | ជាអនុប្រធាន |
| ៣- | លោក នឹម សុផាន់ | ប្រធានសាខាពន្ធដារខេត្ត | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៤- | លោក លី សារី | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | ជាសមាជិក |
| ៥- | លោក ហេង ប៊ុនហោ | ប្រធានមន្ទីរកសិកម្មខេត្ត | ជាសមាជិក |
| ៦- | លោក ឈឹម គ្រីហ្វុង | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | ជាសមាជិក |
| ៧- | លោក សោម សុខេន | អគ្គលេខាធិការរងសាលាខេត្ត | ជាសមាជិក |
| ៨- | លោក ព្រឹម សាលី | អនុប្រធានសាខាពន្ធដារខេត្ត | ជាសមាជិកអចិន្ត្រៃយ៍ |

**ប្រការ២:** អនុគណៈកម្មការមានភារៈកិច្ច :

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត-ក្រុង
- លើកគំរោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់និមួយៗក្នុងខេត្ត-ក្រុង ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធដាក់ជូនគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ពិនិត្យនិងសំរេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនប្រើប្រាស់ ។

**ប្រការ៣:** អនុគណៈកម្មការអាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ ។

**ប្រការ៤:** សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារនិងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ ។

**ប្រការ៥:** អនុគណៈកម្មការត្រូវចូលរួមធ្វើការងារនិងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការនិងត្រូវរាយការណ៍ជាប្រចាំតាម

ខែនិមួយៗ មកគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៦:** ឯកឧត្តម អស់លោក-លោកស្រី ដូចមានរាយនាមក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារៈកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់**

**គង់ វិបុល**

**រដ្ឋលេខាធិការទី១ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នកណ្តាល
- គប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០៦២៤...សហវ.ពដ

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៦

# សេចក្តីជូនដំណឹង

## ស្តីពីការប្រើប្រាស់វិក្កយបត្រសំរាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត)

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និង បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម (អតប) នៅពេលលក់ទំនិញ ឬសេវា សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ត្រូវមានកាតព្វកិច្ចចេញវិក្កយបត្រ អតប ឱ្យអតិថិជនដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចគ្នា និងចេញវិក្កយបត្រធម្មតាឱ្យអតិថិជនជាអ្នកជាប់ពន្ធតាមរបបម៉ៅការ ឬអ្នកទិញប្រើប្រាស់ធម្មតា។ ក្នុងរយៈពេលកន្លងមក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យឃើញថា សហគ្រាសមួយចំនួនបានចេញវិក្កយបត្រត្រឹមត្រូវ ដោយឡែកសហគ្រាសមួយចំនួនទៀតមិនបានចេញ ឬបានចេញវិក្កយបត្រមិនត្រឹមត្រូវ។

ដើម្បីពង្រឹងការគ្រប់គ្រងរបបស្វ័យប្រកាស និងដើម្បីធានាការប្រើប្រាស់វិក្កយបត្រឱ្យបានត្រឹមត្រូវក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំឱ្យសហគ្រាសអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ត្រូវចេញវិក្កយបត្រ អតប ដូចមានចែងក្នុងមាត្រា ៧៧ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងនោះមានខ្លឹមសារសំខាន់ៗជាអាទិ៍ៈ ឈ្មោះ អាសយដ្ឋាន និងលេខអត្ត-សញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់និងអ្នកទិញ លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញ វិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា តម្លៃសរុបប្រាក់ អតប ។ល។ វិក្កយបត្រត្រូវប្រើប្រាស់តាមលំដាប់លេខរៀងឱ្យបានត្រឹមត្រូវ និងត្រូវរក្សាទុកក្នុងរយៈពេល ១០ ឆ្នាំ។

ការមិនចេញវិក្កយបត្រ ឬបានចេញវិក្កយបត្រមិនត្រឹមត្រូវ ត្រូវចាត់ទុកជាអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារតាមមាត្រា ១២៨ នៃច្បាប់ស្តីពីសារពើពន្ធ និងត្រូវរងទោសទណ្ឌដូចមានចែងក្នុងមាត្រា ១៣៣ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងនោះមានការបិទសហគ្រាសក្នុងរយៈពេល ០៧ ថ្ងៃ ការផាកពិន័យជាប្រាក់រហូតដល់ ១០.០០០.០០០ រៀល ឬជាប់ពន្ធធនាគាររហូតដល់ ០១ ឆ្នាំ ឬទោសទាំងពីរ។

ចាប់ពីថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០០៦ តទៅ នាយកដ្ឋានពន្ធដារនឹងធ្វើការពង្រឹងបន្ថែមនូវការចុះអង្កេតត្រួតពិនិត្យដល់ទីកន្លែង ដើម្បីពិនិត្យការប្រើប្រាស់វិក្កយបត្រដូចបានជំរាបជូនខាងលើ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏សូមអំពាវនាវផងដែរដល់លោក លោកស្រីជាអ្នកទិញ សូមមេត្តាទាមទារវិក្កយបត្រពីអ្នកលក់នៅរាល់ពេលទិញទំនិញ ឬសេវា។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសង្ឃឹម និងជឿជាក់ថា លោក លោកស្រី ម្ចាស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់យកចិត្តទុកដាក់អនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ។

**ចម្លងជូន**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
